# បច្ចេកវិទ្យា និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ

នៅក្នុងយុគសម័យឌីជីថល បច្ចេកវិទ្យាបាន នឹងកំពុងដើរតួនាទីយ៉ាងសំខាន់ ចូលរួមដល់ការពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចប្រទេសនីមួយៗ។ ដោយឡែក សម្រាប់កម្ពុជាយើងក៏មានសក្តានុពលក្នុងការចាប់យក និងប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាព សំដៅចូលរួមដល់ការរក្សា និងពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចជាតិ ទាំងនៅក្នុង និងក្រោយដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩។ ខាងក្រោមនេះ ជាការបរិយាយអំពីសន្ទស្សន៍ភាពប្រកួតប្រជែងសកល (Global Competitiveness Index) របស់វេទិកាសេដ្ឋកិច្ចពិភពលោក(World Economic Forum)។
យោងតាម វេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) សន្ទស្សន៍ភាពប្រកួតប្រជែងសកល ត្រូវបានកំណត់ដោយសសរស្តម្ភចំនួន១២ ដែលជាកត្តាកំណត់នូវកម្រិតនៃផលិតភាពរបស់ប្រទេសនីមួយៗ។ កម្រិតនៃផលិតភាពនេះ នឹងចូលរួមកំណត់ភាពរុងរឿងដែលអាចសម្រេចបានតាមរយៈសេដ្ឋកិច្ចប្រទេសមួយ។ សសរស្តម្ភទាំង ១២ មានលក្ខណៈប្រទាក់ក្រឡាគ្នា ជួយបំពេញភាពខ្លាំងឲ្យគ្នាទៅវិញទៅមក ហើយក៏អាចទាញឲ្យខ្សោយដូចគ្នាផងដែរ ដែលចំណុចនេះទាមទារឲ្យមានការគិតគូរពីអន្តរទំនាក់ទំនងរវាងបណ្តុំនៃសសរស្តម្ភ។
គេបានបែងចែកសសរស្តម្ភទាំង ១២ ជា ៣ ដំណាក់កាលនៃការអភិវឌ្ឍ ដូចខាងក្រោម៖



### Institutions

Concepts related to protection of property rights, efficiency and transparency of public administration, independence of the judiciary, physical security, business ethics and corporate governance

- Public institutions
- Private institutions

### Infrastructure

Quality and availability of transport, electricity and communication infrastructures

- Transport infrastructure
- Electricity & telephony infrastructure

### Macroeconomic environment

Fiscal and monetary indicators, savings rate and sovereign debt rating

### Health & primary education

State of public health, quality and quantity of basic education

- Health
- Primary education

### Innovation

Capacity for, and commitment to technological innovation



### Business sophistication

Efficiency and sophistication of business processes in the country

### Higher education & training

Quality and quantity of higher education, and quality and availability of on-the-job training

- Quantity of education
- Quality of education
- On-the-job training

### Market size

Size of the domestic and export markets

- Domestic market size
- Foreign market size

### Goods market efficiency

Factors that drive the intensity of domestic and foreign competition, and demand conditions

- Competition
- Quality of demand conditions

### Technological readiness

Adoption of the technologies by individuals and businesses.

- Technological adoption
- ICT use

### Financial market development

Efficiency, stability and trustworthiness of the financial and banking system

- Efficiency
- Trustworthiness and confidence

### Labour market efficiency

Labour market efficiency and flexibility, meritocracy and gender parity in the workplace

- Flexibility
- Efficient use of talent

weforum.org

**ដំណាក់កាល Factor-driven economy៖** គឺជាដំណាក់កាលនៃការអភិវឌ្ឍ ដែលឧត្តមភាពប្រកួតប្រជែងពឹងអាស្រ័យលើកម្លាំងពលកម្មដែលមិនមានជំនាញ ឬធនធានធម្មជាតិ។ សេដ្ឋកិច្ចនៅដំណាក់កាលនេះ ភាគច្រើនផលិតនូវផលិតផលមូលដ្ឋាន។ កត្តាដើម្បីសម្រេចបាននូវដំណាក់កាលនេះមានដូចជា៖

•សសរស្តម្ភទី១ ស្ថាប័ន (Institutions)៖ គោលគំនិតនៃសសរស្តម្ភនេះទាក់ទងនឹងការការពារកម្មសិទ្ធអចលនទ្រព្យ, ប្រសិទ្ធភាព និងតម្លាភាពនៃប្រព័ន្ធរដ្ឋបាលសាធារណៈ, ភាពឯករាជ្យនៃប្រព័ន្ធយុត្តិធម៌, សន្តិសុខសុវត្ថិភាពសង្គម, ក្រមសីលធម៌អាជីវកម្ម និងអភិបាលកិច្ចល្អ។ គុណភាពនៃសសរស្តម្ភទី១នេះមានឥទ្ធិពលខ្លាំងទៅលើភាពប្រកួតប្រជែងនិងកំណើន។ វាជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់វិនិយោគិន។

•សសរស្តម្ភទី២ ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)៖ សំដៅដល់គុណភាព និងអត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន, បណ្តាញអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍។សសរស្តម្ភទី២នេះក៏ជាផ្នែកមួយជំរុញការសម្រេចចិត្តនៃអ្នកវិនិយោគដែរ តាមរយៈហេដ្ឋារចនាសម្ព័ន្ធសំបូរបែប ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែនិងការដឹកជញ្ជូនតាមផ្លូវអាកាស ដែលអនុញ្ញាតឱ្យអ្នកវិនិយោគអាចបញ្ជូន ឬទទួលបានទំនិញរបស់ពួកគេប្រកបដោយសុវត្ថិភាព និងទាន់ពេលវេលា។ រីឯការផ្គត់ផ្គង់ថាមពលអគ្គិសនីនឹងធានាឱ្យអាជីវកម្ម ឬរោងចក្រអាចដំណើរការបានដោយមិនមានកង្វះខាត និងការរំខាន។ ដោយឡែក បណ្តាញទូរគមនាគមន៍ដ៏រឹងមាំ និងទូលំទូលាយអនុញ្ញាតឱ្យមានលំហូរព័ត៌មានយ៉ាងឆាប់រហ័សដែលបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចទូទៅ ដោយជួយធានាថាអាជីវកម្មអាចប្រាស្រ័យទាក់ទងគ្នាជាប្រចាំ និងជួយដល់ការសម្រេចចិត្ត។

•សសរស្តម្ភទី៣ បរិយាកាសម៉ាក្រូសេដ្ឋកិច្ច (Macroeconomic environment)៖ សំដៅដល់សូចនាករសារពើពន្ធ និងរូបិយវត្ថុ,អត្រានៃការសន្សំ និងចំណាត់ថ្នាក់បំណុលរដ្ឋ។ ស្ថេរភាពនៃបរិយាកាសម៉ាក្រូសេដ្ឋកិច្ច គឺមានសារៈសំខាន់ណាស់សម្រាប់អាជីវកម្មនៅក្នុងប្រទេស និងជាកត្តាប្រកួតប្រជែងមួយសម្រាប់សេដ្ឋកិច្ចជាតិ។

•សសរស្តម្ភទី៤ សុខភាព និងការអប់រំកម្រិតបឋម (Health and Primary Education)៖ សំដៅដល់ប្រព័ន្ធសុខភាពសាធារណៈ គុណភាព និងបរិមាណនៃការអប់រំកម្រិតបឋម។ កម្លាំងពលកម្មប្រកបដោយសុខុមាលភាពល្អមានសារៈសំខាន់ណាស់សម្រាប់ការប្រកួតប្រជែងនិងផលិតភាពក្នុងប្រទេស។ និយោជិតដែលមានជំងឺមិនអាចបំពេញការងារទៅតាមសក្តានុពលរបស់ពួកគេ ហើយនឹងមិនមានផលិតភាព។ សុខភាពខ្សោយនាំឱ្យមានការចំណាយគួរឱ្យកត់សម្គាល់សម្រាប់អាជីវកម្ម ព្រោះថានិយោជិតដែលឈឺច្រើនតែអវត្តមាន ឬប្រតិបត្តិការជាមួយប្រសិទ្ធភាពទាប។ បរិមាណ និងគុណភាពនៃការអប់រំក៏ជាកត្តាបង្កើនប្រសិទ្ធភាពការងាររបស់និយោជិតម្នាក់ៗ ក្នុងការសម្របខ្លួនទៅនឹងដំណើរការ និងបច្ចេកទេសផលិតកម្មកាន់តែប្រសើរ ហើយអនុញ្ញាតឱ្យពួកគេអាចចូលរួមចំណែកបង្កើត ឬអនុវត្តន៍គំនិតច្នៃប្រឌិត។

**ដំណាក់កាល Efficiency-driven economy៖** គឺជាដំណាក់កាលនៃការអភិវឌ្ឍ ដែលភាគច្រើននៅដំណាក់កាលនេះ សេដ្ឋកិច្ចពឹងអាស្រ័យលើការផលិតទំនិញស្តង់ដាដែលជាធនធានដ៏សំខាន់សម្រាប់ឧត្តមភាពប្រកួតប្រជែង។ ដំណើរការផលិតកម្មកាន់តែមានប្រសិទ្ធភាព ហើយទំនិញកាន់តែមានគុណភាព។ កត្តាដើម្បីសម្រេចបាននូវដំណាក់កាលនេះមានដូចជា៖

•សសរស្តម្ភទី៥ ការអប់រំ និងការបណ្តុះបណ្តាលកម្រិតឧត្តម (Higher Educationand Training)៖ សំដៅដល់គុណភាព និងបរិមាណនៃការអប់រំកម្រិតខ្ពស់, និងលទ្ធភាពនៃការបណ្តុះបណ្តាលនៅនឹងកន្លែងការងារ (On-the-job training; Reskilling & Upskilling)។ ការអប់រំ និងការ

បណ្ដុះបណ្ដាលដែលមានគុណភាពខ្ពស់មានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចដែលចង់បង្កើនខ្សែសង្វាក់តម្លៃលើសពីដំណើរការផលិតកម្មបែបសាមញ្ញៗ។ បរិបទសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះតម្រូវឱ្យប្រទេសនានាអប់រំបណ្ដុះបណ្ដាលកម្លាំងពលកម្ម ដែលអាចបំពេញភារកិច្ចស្មុគស្មាញ និងអាចសម្របខ្លួនបានឆាប់រហ័សទៅនឹងការផ្លាស់ប្ដូរបរិយាកាសការងារ និងការវិវត្តនៃតម្រូវការផ្នែកប្រព័ន្ធផលិតកម្ម។

*•សសរស្ដម្ភទី៦ ប្រសិទ្ធភាពនៃទីផ្សារទំនិញ* (Goods market efficiency)៖ សំដៅដល់កត្តាពង្រឹងការប្រកួតប្រជែងក្នុងស្រុកនិងក្រៅប្រទេស (Healthy market competition) តាមរយៈការបើកចំហទីផ្សារឲ្យមានការប្រកួតប្រជែងរវាងសហគ្រាសនិងផលិតកម្មនានា ដើម្បីបំពេញតម្រូវការអ្នកប្រើប្រាស់ ដែលជាមុខព្រួញនៃការបង្កើនភាពប្រកួតប្រជែង។ ក្នុងករណីនេះ វិធានការគាំពារនិយមជ្រុលអាចបង្អាក់ប្រសិទ្ធភាពទីផ្សារសេរី។

*•សសរស្ដម្ភទី៧ ប្រសិទ្ធភាពទីផ្សារការងារ* (Labor market efficiency) ៖ សំដៅដល់ភាពបត់បែននិងប្រសិទ្ធភាពនៃទីផ្សារកម្លាំងពលកម្ម, ការប្រើប្រាស់ធនធានដែលមានទេពកោសល្យប្រកបដោយប្រសិទ្ធផល, ការលើកទឹកចិត្ត និងកាអនុវត្តប្រព័ន្ធគុណូបធិបតេយ្យ (meritocracy) និងការធានាភាពស្មើគ្នារវាងបុរស និងស្ត្រីនៅកន្លែងការងារ។

*•សសរស្ដម្ភទី៨ ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ* (Financial market development) ៖ សំដៅដល់ប្រសិទ្ធភាព, ស្ថេរភាពនិងភាពជឿទុកចិត្តរបស់ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារ ដែលជាប្រភពបែងចែកការប្រើប្រាស់ធនធាននៅក្នុងចរន្តសេដ្ឋកិច្ច។

*•សសរស្ដម្ភទី៩ ការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យា* (Technological readiness)៖ សំដៅទៅដល់លទ្ធភាពសម្របខ្លួន ក្នុងការចាប់យក និងប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ (Technological Adoption) ដើម្បីពង្រឹងផលិតភាព ពិសេសការផ្ទេរបច្ចេកវិទ្យាតាមរយៈ FDI ។

*•សសរស្ដម្ភទី១០ ទំហំទីផ្សារ* (Market size)៖ សំដៅដល់ទំហំនៃទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ដែលជាកត្តាជះឥទ្ធិពលដល់កំណើន និងភាពប្រកួតប្រជែង តាមរយៈ Economy of scale។

**ដំណាក់កាល Innovation-driven economy៖** គឺជាដំណាក់កាលនៃការអភិវឌ្ឍ ដែលមានសមត្ថភាពក្នុងការបង្កើតនូវផលិតផលបច្ចេកវិទ្យាសំខាន់ៗ។ នៅដំណាក់កាលនេះ គេប្រើប្រាស់ជំនាញ និងបច្ចេកវិទ្យាកម្រិតខ្ពស់ក្នុងការផលិតនូវផលិតផលដែលជាឧត្តមភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចជាតិ។ កត្តាដើម្បីសម្រេចបាននូវដំណាក់កាលនេះមានដូចជា៖

*•សសរស្ដម្ភទី១១ ទំនើបកម្ម និងភាពស្វាហាប់នៃអាជីវកម្ម* (Business sophistication & dynamism)៖ សំដៅដល់ប្រសិទ្ធភាព និងទំនើបកម្មនៃដំណើរការអាជីវកម្មនៅក្នុងប្រទេសដែលជាទូទៅត្រូវបានកំណត់ដោយសមាសធាតុ២ គឺ៖ ទី១.គុណភាពនៃបណ្ដាញអាជីវកម្ម ឬពាណិជ្ជកម្មនៅក្នុងប្រទេស និងទី២.គុណភាពនៃប្រព័ន្ធប្រតិបត្តិការនិងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុននីមួយៗ។

*•សសរស្ដម្ភទី១២ នវានុវត្តន៍* (Innovation)៖ សំដៅដល់សមត្ថភាព និងការប្ដេជ្ញាចិត្តចំពោះរបកគំហើញផ្នែកបច្ចេកវិទ្យាថ្មីៗ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ការលោតផ្លោះបង្កើនផលិតភាពនៅក្នុងខ្សែសង្វាក់តម្លៃ ស្របតាមបរិបទនៃបដិវត្តន៍ឧស្សាហកម្ម៕

---

www.cambodia4point0.org
កម្ពុជា ៤.0 - Cambodia 4.0
cambodia_4.0
កម្ពុជា ៤.0 - Cambodia 4.0
cambodia4point0